**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៣ អនក្រ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពាណិជ្ជកម្មនៅបណ្តាប្រទេសអាស៊ាន

~~~~~

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មASEAN នៅបណ្តាប្រទេស ជា សមាជិកអាស៊ាន ។

**ប្រការ ២:** គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធាន
~~~~~

| | | |
|---|---|---|
| ២-ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាអនុប្រធាន |
| ៣-ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាអនុប្រធាន |
| ៤-ឯកឧត្តម ម៉ៅ ថូរា | អគ្គនាយក ក្រសួងពាណិជ្ជកម្ម | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥-ឯកឧត្តម តោស៊ី សារឿត | អគ្គនាយក ក្រសួងទេសចរណ៍ | ជាសមាជិក |
| ៦-ឯកឧត្តម ហង្ស សុត | អគ្គនាយក ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក |
| ៧-ឯកឧត្តម គុំ សាវុន | អគ្គនាយក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៨-លោក នេត សារឿន | អគ្គនាយករង ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៩-លោក កែ ផៃ | អគ្គនាយករង ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ១០-លោក ម៉ុន ឈាង | អគ្គនាយករង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ១១-លោក ស៊ឹម ទ៉ា | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១២-លោក ឈឹក សុខុម | ប្រធាននាយកដ្ឋានទីផ្សារ និងផ្សព្វផ្សាយ ក្រសួងទេសចរណ៍ | ជាសមាជិក |
| ១៣-លោក ដែត សារិន | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក |
| ១៤-លោក ញាណ ទិព្វល | អនុប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ១៦-លោក ហេង សោភ័ណ្ឌ | អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ជាសមាជិក |
| ១៧-លោក ជា គៀត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និង ជំរុញវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១៨-លោក អៀង ស៊ុនលី | អនុប្រធាននាយកដ្ឋានថវិការនិយ័តកម្ម និងហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួងនេះ មានលេខាធិការដ្ឋាននៅនាយកដ្ឋានជំរុញការនាំចេញ នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៤ :** គណៈកម្មការអន្តរក្រសួងនេះ មានភារៈកិច្ចដូចតទៅ :

- ចូលរួមពិព័រណ៍ពាណិជ្ជកម្ម ASEAN នៅទីក្រុងបាងកក ឆ្នាំ២០០២ ក៏ដូចជាពិព័រណ៍ ពាណិជ្ជកម្ម ASEAN នាឆ្នាំបន្តបន្ទាប់ ត្រូវស្ថិតនៅជានិរន្តន៍ ដើម្បីបំរើការតាំងពិព័រណ៍ពាណិជ្ជកម្ម ASEAN
- ធ្វើទំនាក់ទំនងជាមួយភាគីម្ចាស់ផ្ទះ ដើម្បីចូលរួមពិព័រណ៍ពាណិជ្ជកម្ម ASEAN
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ និងក្រុមហ៊ុននានាដែលពាក់ព័ន្ធ ដើម្បីត្រៀមលក្ខណៈក្នុងការចូលរួមពិព័រណ៍ពាណិជ្ជកម្ម ASEAN នេះ
- ទទួលខុសត្រូវ និងចាត់ចែងពីការងាររៀបចំសាងសង់ស្តង់ (NATIONAL PAVILLION) និងសំរបសំរួលការទទួលខុសត្រូវចំពោះស្តង់ឯកជន (PRIVATE SECTOR)
- ជំរុញការតាំងពិព័រណ៍របស់ព្រះរាជាណាចក្រកម្ពុជាយើង អោយបានទទួលជោគជ័យយ៉ាងត្រចះត្រចង់នៅទីក្រុងបាងកកខាងមុខនេះ ក៏ដូចជាពិព័រណ៍ពាណិជ្ជកម្មអាស៊ាន នាឆ្នាំបន្តបន្ទាប់នៅបណ្តាប្រទេសជាសមាជិកអាស៊ាន
- លើកយោបល់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសំរេចក្នុងករណីចាំបាច់ និងធ្វើរបាយការណ៍បូកសរុបលទ្ធផលជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងពាក់ព័ន្ធ នៅពេលពិព័រណ៍ពាណិជ្ជកម្មមួយលើកៗបញ្ចប់ ។

**ប្រការ ៥ :** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យ និងផ្តល់ថវិកាសំរាប់ចំណាយក្នុងការចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្មនេះ ។

**ប្រការ ៦ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួន សំរាប់ជំនួយការងារ ។

**ប្រការ ៧ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ដែលពាក់ព័ន្ធ និង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានចែងឈ្មោះ

ក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ